# ទន្លេមេគង្គ ៖ ទឹក និងក្ដីស្រលាញ់

បណ្ឌិត ជិន សុជាតិ
មន្ត្រីស្រាវជ្រាវវិទ្យាស្ថានសិក្សាចិន នៃរាជបណ្ឌិត្យសភាកម្ពុជា

អរិយធម៌នៃមនុស្សជាតិ ភាគច្រើនគឺបានកើតឡើងនៅតំបន់មាត់ទន្លេ ឬតំបន់ដីសណ្ដទន្លេដូចជា អរិយធម៌អេហ្ស៊ីបបុរាណក្នុងតំបន់ដីសណ្ដទន្លេនីល អរិយធម៌មេសូប៉ូតាមី ក្នុងចន្លោះទន្លេទីក និងអឺប្រាត អរិយធម៌ចិននៅតាមដងទន្លេលឿង និងអរិយធម៌ខ្មែរ ក្នុងតំបន់ដីសណ្ដទន្លេមេគង្គជាដើម។

របបទឹកធម្មជាតិនៃទន្លេមេគង្គតែងតែបានបង្កើតរដូវទឹកឡើង(រដូវទឹកជំនន់) និងរដូវទឹកស្រក ស្ទើរតែទៀងទាត់។ ទន្លេមេគង្គបានរួមចំណែកដ៏ធំធេងក្នុងការនាំទឹកឱ្យលិចជន់ក្នុងតំបន់ទន្លេមេគង្គក្រោម នៅរវាងខែសីហា-វិច្ឆិកា។ ទឹកជំនន់ដ៏សន្ធឹកសន្ធាប់នេះ បានហូរចូលស្រោចស្រពបឹងបួរនានា រួមទាំងបឹងទន្លេសាបដ៏ធំមួយនៅអាស៊ីអាគ្នេយ៍ តាមរយៈទន្លេសាប ដែលធ្វើឱ្យផ្ទៃទឹកបឹងដ៏ធំនេះកើនដល់ចំនួនប្រហែល ១៦០០០គីឡូម៉ែត្រការ៉េ ប៉ុន្តែនៅរដូវប្រាំងមានចំនួនប្រហែលតែ ២៥០០គីឡូម៉ែត្រការ៉េប៉ុណ្ណោះ [1] ។ បន្ទាប់មកចាប់ពីប្រហែលពាក់កណ្ដាលខែវិច្ឆិកាទឹកនៅតាមបឹងបួរនានាក៏ចាប់ផ្ដើមហូរស្រកចុះវិញ បឹងទន្លេសាបចាប់ផ្ដើមស្រកទឹកហូរត្រឡប់ទៅទន្លេមេគង្គវិញតាមរយៈទន្លេសាបដដែល។ វដ្ដនៃទឹកទន្លេមេគង្គនេះវាបានបង្កើតឱ្យមានភាពសម្បូរបែបនៃជីវៈចម្រុះ រួមទាំងប្រពៃណីវប្បធម៌នៃប្រជាជាតិរាប់សិបលាននាក់ដែលរស់តាមដងទន្លេនេះ ជាពិសេសសម្រាប់ប្រជាជនខ្មែរ។

ជនជាតិខ្មែរមានទម្លាប់ធ្វើផ្ទះមានសសរខ្ពស់ពីដី ព្រោះពួកគេដឹងច្បាស់ណាស់ថា ទឹកជំនន់គឺមានជារៀងរាល់ឆ្នាំ។ ទឹកជំនន់បាននាំមកនូវដីល្បាប់ដ៏មានជីជាតិដែលធ្វើឱ្យជនជាតិខ្មែរមានទម្លាប់ក្នុងការធ្វើស្រែឡើងទឹក(ស្រូវទុំពេលទឹកជំនន់) និងស្រែប្រដេញទឹក(ស្រូវទុំពេលរដូវប្រាំង)។ ក្រៅពីស្រូវប្រជាជននៅតាមដងទន្លេបានដាំនូវដំណាំបន្លែ ដំណាំឈើហូបផ្លែ និងដំណាំកសិ-សិប្បកម្ម និងកសិ-ឧស្សាហកម្មជាច្រើនទៀត។ ទឹកជំនន់ក៏បានធ្វើឱ្យមានការធំធាត់នៃសត្វវារីជាតិ រួមទាំងត្រីដ៏សម្បូរបែប។ នៅរដូវទឹកស្រកគឺជាពេលវេលាដ៏សប្បាយរីករាយសម្រាប់ប្រជាជនកម្ពុជាក្នុងការនេសាទត្រី។ ត្រីបានបង្កើតឱ្យមានវប្បធម៌ច្រើនយ៉ាង ជាពិសេសវប្បធម៌ប្រហុក ត្រីងៀត និងត្រីឆ្អើរជាដើម។

នៅរដូវទឹកស្រក ទឹកតាមបឹងបួរតូចធំក៏ចាប់ផ្ដើមហូរស្រកចុះ ជាសញ្ញាប្រាប់ឱ្យដឹងថា រដូវប្រមូលផលនានាក៏នឹងខិតជិតចូលមកដល់។ ដើម្បីសម្ដែងមនោសញ្ចេតនាដឹងគុណ និងក្ដីស្រលាញ់ចំពោះទន្លេមេគង្គ

[1] https://www.globalnature.org/en/living-lakes/asia/tonle-sap

និងទន្លេសាប ដែលបានផ្តល់ដល់ជីវភាពរស់នៅ សុខុមាលភាព និងសេចក្តីរុងរឿង ខ្មែរបានធ្វើពិធីបុណ្យទន្លេ និងពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ជារៀងរាល់ឆ្នាំ។

ក្នុងពិធីបុណ្យអុំទូក ប្រជាជនខ្មែរក៏ដូចជាមន្ត្រីក្នុងស្ថាបនធំៗរបស់រដ្ឋាភិបាល តែងតែធ្វើនូវប្រទីប តូច ធំ បណ្តែតបួងសួងនាពេលរាត្រីមានភ្លើងចម្រុះពណ៌ គួរជាទីគយគន់ និងមានបាញ់កាំជ្រួច ក្នុងគោល បំណងសំដែងនូវការដឹងគុណដល់ព្រះម៉ែគង្គា (Goddess Ganga ) ដែលថែរក្សាទន្លេមេគង្គ និងទន្លេឯ ទៀតក្នុងប្រទេសកម្ពុជា និងការអបអរនូវភាពសំបូររុងរឿងរបស់ប្រជាជាតិតាមរយៈភាពអំណោយផល របស់ទន្លេមេគង្គ។ ក្នុងពិធីបុណ្យអុំទូកនេះផងដែរក៏មានរៀបចំនូវកម្មវិធីសំពះព្រះខែ និង អកអំបុក ដែល ប្រព្រឹត្តទៅនៅម៉ោង១២វំលងអាធ្រាត ។ នៅក្នុងពិធីអកអំបុកគេអាចលេងល្បែងជាក្រុម ដែលឱ្យសមាជិក ង៉ើយអកអំបុក និងញុំាចេកពេញមាត់(បញ្ជាក់អំពីភាពសម្បូរសប្បាយ) ហើយប្រើវិធីចំអកឡកលើយធ្វើ យ៉ាងណាឱ្យអ្នកអកអំបុកឈ្លក់សើច ជាការសន្មត់ថាចាញ់ ។ ក្នុងពិធីនេះពួកគេតែងតែមានពាក្យសួរគ្នាជា និច្ចថា ឆ្នាំក្រោយមានទឹកគ្រប់គ្រាន់ទេ? ឬថា ឆ្នាំក្រោយភ្លៀងល្អឬទេ? [2] ពិធីអកអំបុកក៏ជាកម្មវិធីមួយ សម្រាប់ជាឱកាសរបស់យុវជនប្រុសស្រីកសិករខ្មែរបានជួបជុំសម្លឹងរកគ្នាក្នុងសេចក្តីស្នេហា ក្រោមក្រសែ ភ្នែកចាស់ៗ ជាឪពុកម្តាយដើម្បីរៀបចំទុកដាក់កូនចៅនារដូវរំហើយខាងមុខ។

ទឹកទន្លេមេគង្គពិតជាបានផ្តល់នូវក្តីស្រលាញ់ដល់មនុស្សជាតិដែលត្រូវមានការយកចិត្តទុកដាក់ ជាសកល។ ហេតុនេះគណកម្មាធិការមេគង្គបានបានរៀបចំឱ្យមានឡើងតាំងពីឆ្នាំ១៩៥៧ ក្រោមការ គ្រប់គ្រងរបស់អង្គការសហប្រជាជាតិ [3] ។ តែយ៉ាងណាក្នុងពេលថ្មីៗនេះទន្លេមេគង្គបានក្លាយជា ភូមិសាស្ត្រនយោបាយរវាងសហរដ្ឋអាម៉េរិក និងចិនរួចមកហើយ។ គួរបញ្ជាក់ថា មានយន្តការពីរ ធ្វើរឿង ទន្លេមេគង្គតែមួយ ដែលទី១គឺ គណកម្មការទន្លេមេគង្គ ដែលបង្កើតឆ្នាំ១៩៩៥ មានសមាជិក កម្ពុជា វៀត ណាម ឡាវ ថៃ ប៉ុន្តែមីយ៉ាន់ម៉ា និងប្រទេសចិនដែលមានពាក់ព័ន្ធនឹងទន្លេមេគង្គនេះមិនមែនជាសមាជិក គណកម្មការទន្លេមេគង្គនេះទេ។ គណកម្មការទន្លេមេគង្គត្រូវបានគេមើលឃើញថា ទទួលបានជំនួយភាគ ច្រើនពីសហរដ្ឋអាម៉េរិក ជប៉ុន និងប្រទេសកូរ៉េខាងត្បូង ។ ដោយឡែក នៅឆ្នាំ២០១៤ មានការបង្កើតកិច្ច សហប្រតិបត្តិការ មេគង្គ ឡានឆាង ដែលគាំទ្រដោយប្រទេសចិន [4]។

យើងត្រូវទទួលស្គាល់ថាបម្រែបម្រួលនៃអាកាសធាតុ តម្រូវការទឹក និងតម្រូវការអគ្គីសនីបានធ្វើឱ្យ យើងរំពឹងទុកថារបបទឹកទន្លេមេគង្គនឹងមិនមានវដ្តធម្មជាតិដូចមុនទៀតឡើយ ជាពិសេសគិតត្រឹមពីឆ្នាំ

---

[2] មៀច ប៉ុណ្ណ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

[3] https://www.mrcmekong.org/

[4] http://www.lmcchina.org/eng/

២០១២មក[5]។ ការបកស្រាយអំពីលំហូរទឹកទន្លេមេគង្គតាមដំណើរធម្មជាតិរបស់អាម៉េរិកដែលលើកឡើងថា ការឃាំងទឹកដោយទំនប់វារីអគ្គិសនីនឹងធ្វើឱ្យប្រទេសនៅទន្លេមេគង្គក្រោមខ្វះទឹក និងការបកស្រាយរបស់ចិនដែលថា ទំនប់វារីអគ្គិសនីអាចជួយកាត់បន្ថយគ្រោះរាំងស្ងួត។ កាសែត People's Daily ដែលជា កាសែតផ្លូវការរបស់គណបក្សកុម្មុយនិស្តចិន បានសរសេរថា៖ «ការស្រាវជ្រាវបានរកឃើញថា ទំនប់ទឹកទន្លេនៅក្នុងប្រទេសចិនជួយកាត់បន្ថយទឹកជំនន់ និងគ្រោះរាំងស្ងួត» [6] ។ ការសិក្សាស្រាវជ្រាវដែលធ្វើឡើងដោយសាកលវិទ្យាល័យ Tsinghua និង វិទ្យាស្ថានធនធានទឹកចិន បានរកឃើញថា ទំនប់ទឹកចិននៅពេលអនាគតអាចនឹងជួយកាត់បន្ថយគ្រោះរាំងស្ងួត)[7]។

ទន្លេមេគង្គមានប្រភពមកពីប្រទេសចិន វារីអគ្គិសនីជាច្រើនបានសាងសង់ក្នុងទឹកដីចិន និងបណ្ដាប្រទេសមួយចំនួនទៀតនៅតាមបណ្ដោយទន្លេមេគង្គរួចហើយ។ បើតាមយន្តការរបស់អាម៉េរិក តើទំនប់វារីអគ្គិសនីទាំងនោះនឹងត្រូវវាយកម្ទេច? ឬក៏ត្រូវបញ្ចប់ទំនាក់ទំនងជាមួយប្រទេសចិន? ប្រហែលជាមិនអាចឡើយ។ ហេតុនេះ យើងត្រូវទទួលយកការពិតថា លំហូរទឹកទន្លេមេគង្គតាមរបៀបបច្ចេកទេសនៃវារីអគ្គិសនី វានឹងមកជំនួសឱ្យលំហូរទឹកតាមបែបធម្មជាតិដោយចៀសមិនផុតឡើយ។ អ្វីដែលសំខាន់សួរថា លំហូរទឹកតាមរបៀបបច្ចេកទេសនៃវារីអគ្គិសនីថ្មីនេះ វានឹងមានអ្វីខ្លះកើតឡើងសម្រាប់មនុស្សជាតិរាប់លាននាក់នៅទន្លេមេគង្គក្រោម? តើគេត្រូវធ្វើរឿងអ្វីខ្លះដើម្បីជំនួសឱ្យការបម្រែបម្រួលថ្មីទាំងនេះ?

វិទ្យុមិត្តភាពកម្ពុជា-ចិន បានលើកឡើងថា "យើងផឹកទឹកទន្លេតែមួយ សូមឱ្យមិត្តភាព និង មនោសញ្ចេតនាជិតស្និទ្ធនឹងគ្នា" [8] ហេតុនេះ កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ គឺជាយន្តការមួយដែលត្រូវបានបំពេញតួនាទីជាវិជ្ជមាន ចំពោះការបង្កើតការអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ទន្លេឡានឆាង-មេគង្គ ដោយរួមគ្នាបង្កើតសហគមន៍វាសនាប្រទេសទន្លេឡានឆាង-មេគង្គ បង្កើននូវសុភមង្គលរបស់ប្រជាជននៃបណ្ដាប្រទេសតាមដងទន្លេឡានឆាង-មេគង្គ ព្រមទាំងបានរក្សា និងជំរុញនូវស្ថេរភាពអភិវឌ្ឍន៍ និងសន្តិភាពក្នុងតំបន់ផងដែរ។ កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គអាចជាការឆ្លើយតបនឹងអ្វីដែលនាំឱ្យមានការចោទប្រកាន់ចិនថា បានធ្វើរឿងអវិជ្ជមាននានាលើបញ្ហាទន្លេមេគង្គ។ ហេតុនេះកិច្ចការដែលចិនត្រូវធ្វើប្រឆាំងនឹងរឿងចោទប្រកាន់នេះ តាមរយៈយន្តការមេគង្គ-ឡានឆាង ប្រទេសចិនគួរតែធ្វើរឿងបែបវិជ្ជមានជំនួសវិញ ដែលក្នុងនោះមាន ៖

---

[5] https://www.mrcmekong.org/assets/Publications/Understanding-Mekong-River-hydrological-conditions_2020.pdf

[6] http://en.people.cn/n3/2020/0824/c90000-9737767.html

[7] https://www.reuters.com/article/us-mekong-river-diplomacy-insight-idINKCN24P0K7

[8] វិទ្យុមិត្តភាពកម្ពុជាចិន ភ្នំពេញ FM៩៦.៥ Mhz " ពិធីប្រគល់រង្វាន់ជូនជយ័លាភី ១៥រូប នៅក្នុងការប្រកួតស្នាដៃវីដេអូខ្លីស្ដីអំពី សន្យាជួបគ្នានៃទន្លេឡានឆាង-មេគង្គ " ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៩

ទី១ បន្តចែករំលែកពត៌មានទឹកដ៏ជាក់លាក់រៀងរាល់ឆ្នាំ និងយូរអង្វែង ដើម្បីឱ្យយើងងាយស្រួលធ្វើផែនការនៅក្នុងការអភិវឌ្ឍទន្លេមេគង្គភាគខាងក្រោម។

ទី២ ការចែករំលែកទឹកប្រកបដោយតម្លាភាព ចៀសវាងការចោទប្រកាន់ថាមានរឿងអយុត្តិធម៌។ ឧទាហរណ៍ករណីខែកុម្ភៈ ឆ្នាំ២០២១ ទន្លេមេគង្គស្រកដល់កម្រិត «គួរឱ្យព្រួយបារម្ភ» ជាពិសេសក្នុងប្រទេសឡាវ និងក្នុងតំបន់ចំនួន៤ក្នុងប្រទេសកម្ពុជាដូចជា៖ នៅខេត្ត កំពង់ចាម នៅអ្នកលឿង នៅព្រែកក្តាម និងនៅទន្លេបាសាក់ ក្នុងទីក្រុងភ្នំពេញ នេះបើតាមការអះអាងរបស់គណៈកម្មការទន្លេមេគង្គ [9] ។

ទី៣ បង្កើតស្ថាប័នស្រាវជ្រាវ និងបណ្តុះបណ្តាលនូវរបៀបធ្វើកសិកម្មថ្មីជាពិសេសការផលិតឧបករណ៍បច្ចេកទេសសន្សំសំចៃទឹកកសិកម្ម និងពូជដំណាំដែលស៊ាំនឹងបម្រែបម្រួលអាកាសធាតុ។

ទី៤ ការផ្តល់ជំនួយបច្ចេកទេសដល់ការបង្កើតថាមពលកកើតឡើងវិញ ដូចជាបន្ទះសូឡា សម្រាប់លើកកម្ពស់ជីវភាពរបស់ប្រជាជនតាមតំបន់អាងទន្លេមេគង្គភាគខាងក្រោម។

ទី៥ ផ្តល់ជំនួយសម្រាប់បណ្តាញគមនាគមន៍តាមដងទន្លេ សម្រាប់ជាប្រយោជន៍ទេសចរណ៍ពាណិជ្ជកម្ម និងទំនាក់ទំនងផ្សេងៗ។

ទី៦ អាងស្តុកទឹកធំៗគួរតែត្រូវបានស្ថាបនាសម្រាប់សន្តិសុខទឹក ការពារពេលដែលទឹកជំនន់មេគង្គជន់ឡើងចូលមិនដល់ ឬពេលដែលមានការខ្វះខាតទឹកដោយប្រការណាមួយ។

ទី៧ ដោយសារចរន្តលំហូរទឹកថ្មីប៉ះពាល់ដល់ផលនេសាទ យន្តការមេគង្គ ឡានឆាង គួរតែបង្កើតកម្មវិធីជីកស្រះ និងការចិញ្ចឹមត្រី ការបង្កើតតំបន់អភិរក្សសម្រាប់ពូជត្រី និងសត្វវាឬជាតិដទៃទៀត។

---

[9] https://www.rfi.fr/km គណៈកម្មការទន្លេមេគង្គព្រួយបារម្ភចំពោះកម្រិតទឹកធ្លាក់ចុះទាបនៅតំបន់ចំនួន៤ក្នុងប្រទេសកម្ពុជា។